ភ្នំពេញ ថ្ងៃអង្គារ ០៨រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣

**លិខិតចំហគោរពជូនចំពោះ**

**លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

**ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីនៃក្រសួងព័ត៌មាន**

**លោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

**ឯកឧត្តម ជា វ៉ាន់ដេត រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**

**សំណើ៖ ស្នើមានចំណាត់ការទៅលើលោក ផេង វណ្ណៈ ដែលជាម្ចាស់គេហទំព័រ Pheng Vannak News ចំពោះការប្រើប្រាស់មាតិកាមិនសមរម្យ ការប្រមាថ មាក់ងាយ និងបៀតបៀនទៅលើស្ត្រីអ្នកសារព័ត៌មាន។**

យើងខ្ញុំអង្គការសង្គមស៊ីវិលដែលកំពុងធ្វើការដើម្បីលើកកម្ពស់សិទ្ធិស្ត្រីនិងសមភាពយេនឌ័រនៅកម្ពុជាដែលមានរាយនាមដូចខាងក្រោម បានទទួលស្គាល់នូវឆន្ទៈដ៏ខ្ពង់ខ្ពស់និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់សិទ្ធិស្ត្រី និងសមភាពយេនឌ័រនៅគ្រប់វិស័យ ជាពិសេសការបំពេញកាតព្វកិច្ចក្នុងនាមជារដ្ឋភាគី នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី និងតាមរយៈការអនុវត្តច្បាប់ និងគោលនយោបាយជាតិនានា។

យោងតាមរបាយការណ៍របស់ក្រសួងព័ត៌មានក្នុងឆ្នាំ២០២១ ក្នុងចំណោមអ្នកសារព័ត៌មានសរុបចំនួន ៥០០០ (ប្រាំពាន់)នាក់ មានស្ត្រីជាអ្នកសារព័ត៌មានតែ ៤៧០នាក់ ដែលស្មើនឹង ៩.៤ ភាគរយប៉ុណ្ណោះ។ តួលេខនេះបានបង្ហាញពីវត្តមានរបស់ស្ត្រីដែលចូលរួមក្នុងវិស័យសារព័ត៌មាននៅមានតិចនៅឡើយក្នុងប្រទេសកម្ពុជា។ មិនត្រឹមតែប៉ុណ្ណោះ ក្នុងចំណោមស្ត្រីជាអ្នកសារព័ត៌មានទាំងនេះ ពួកគេបានរាយការណ៍អំពីបញ្ហាប្រឈមជាច្រើនដែលពួកគេជួបប្រទះ ជាពិសេសទាក់ទងនឹងការរើសអើងផ្អែកលើយេនឌ័រ ការបៀតបៀន និងគំរាមកំហែង[1]។ ប្រការទាំងនេះ ធ្វើឲ្យប៉ះពាល់ដល់ស្ថានភាពផ្លូវកាយ ផ្លូវចិត្ត និងលទ្ធភាពក្នុងការបំពេញវិជ្ជាជីវៈរបស់ពួកគេ ហើយក៏អាចជាកត្តាបន្ទប់បង្អាក់ស្ត្រីផ្សេងទៀត មិនឲ្យចាប់អាជីពការងារក្នុងវិស័យសារព័ត៌មានផងដែរ។

ជាមួយនឹងបញ្ហាប្រឈមទាំងនេះ យើងខ្ញុំមានការខកចិត្តនិងព្រួយបារម្ភយ៉ាងខ្លាំងដែលលោក **ផេង វណ្ណៈ** បានប្រើមាតិកាប្រមាថមាក់ងាយនិងបៀតបៀនទៅលើស្ត្រីអ្នកសារព័ត៌មានម្នាក់យ៉ាងធ្ងន់ធ្ងរ នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមហ្វេសប៊ុកផ្ទាល់ខ្លួនរបស់លោក (Vannak Pheng) ដែលមានខ្លឹមសារ *"ជាស្រីក្មេងមានរូបសម្បត្តិស្អាតបាតដែរ តែចរិកព្រៃផ្សៃ...........ចរិកថោកទាបដូចនាង អាណា យកធ្វើប្រពន្ធងាប់ហើយ..."* ។

[1] Khmertimes: https://www.khmertimeskh.com/50769694/support-for-female-journalists-sought/
Phnom Penh Post: https://www.phnompenhpost.com/national/female-journos-share-woes-seek-improvements

យើងខ្ញុំមើលឃើញថាសកម្មភាពប្រមាថមាក់ងាយខាងលើនេះ ធ្វើឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើកិច្ច ប្រឹងប្រែងនានារបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី ឆ្ពោះទៅសម្រេចឲ្យបានតាមគោលដៅទី ៥ នៃការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ ដែលក្នុងនោះក៏ធ្វើឡើងតាមរយៈការលុបបំបាត់ផ្នត់គំនិតរើសអើងផ្អែកលើយេនឌ័រ រួមទាំងតាមប្រព័ន្ធអនឡាញផងដែរ។ ជាងនេះទៅទៀត ការប្រើប្រាស់ពាក្យសម្តីប្រមាថរបស់ លោក ផែង វណ្ណៈ ដូចខាងលើនេះ គឺជាទង្វើដែលមិនអាចលើកលែងបាន អសីលធម៌ និងបំពានយ៉ាងខ្លាំងទៅលើក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន ជាពិសេស បំពានទៅលើក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី ដែលក្រសួងកិច្ចការនារី និងក្រសួងព័ត៌មានបានរួមគ្នាបង្កើតឡើងកាលពីខែកក្កដា ឆ្នាំ២០១៧ និងដោយរួមទាំងបានបង្កើតក្រុមការងារដើម្បីអនុវត្ត ពិនិត្យ តាមដានដោះស្រាយបញ្ហានៃការរំលោភបំពានលើក្រមប្រតិបត្តិនេះដែរ។ ជាងនេះទៅទៀតទង្វើទាំងនេះរបស់លោក ផែង វណ្ណៈ បានបណ្តាលឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្តិយសសេចក្តីថ្លៃថ្នូរបស់បុគ្គល បន្ទាបតម្លៃស្ត្រី និងសង្គមជាតិទាំងមូលដែលផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១ *"...ពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់......ការប្រើប្រាស់សិទ្ធិសេរីភាពរបស់មនុស្សម្នាក់ៗមិនត្រូវអោយប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ.. "*។

អាស្រ័យហេតុដូចនេះ យើងខ្ញុំសូមស្នើដល់លោកជំទាវរដ្ឋមន្ត្រី និង ឯកឧត្តមរដ្ឋមន្ត្រី មេត្តាចាត់វិធានការផ្លូវច្បាប់តឹងរ៉ឹងទៅលើ លោក **ផែង វណ្ណៈ** ដើម្បីផ្តល់យុត្តិធម៌ដល់ស្ត្រីដែលទទួលរងការប្រមាថ និង ការបៀតបៀន រួមទាំងបង្កើតគម្រូភាពល្អនៅក្នុងសង្គម រួមមាន៖

១. ក្រុមការងារតាមដានរាយការណ៍អំពើហិង្សាលើស្ត្រីនៃក្រសួងកិច្ចការនារី និងក្រសួងព័ត៌មាន ចាត់វិធានការចំពោះទង្វើរបស់លោក ផែង វណ្ណៈ ដើម្បីអនុវត្តឲ្យស្របតាមក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី និង ទប់ស្កាត់រាល់មាតិកាដែលបង្កប់នូវខ្លឹមសារប្រមាថមាក់ងាយដល់ស្ត្រី និងបុគ្គលគ្រប់អត្តសញ្ញាណយេនឌ័រកុំឲ្យកើតមានឡើងបន្តទៀត។ ។

**២.** បង្គាប់ឲ្យលោក ផែង វណ្ណៈ ទទួលស្គាល់កំហុស កែតម្រូវពាក្យពេចន៍ប្រមាថ មាក់ងាយ និង ធ្វើការសូមទោសជាសាធារណៈចំពោះស្ត្រីជាអ្នកសារព័ត៌មានដែលរងគ្រោះ និងសាធារណៈជនទូទៅចំពោះទង្វើដ៏អសីលធម៌របស់គាត់។

**៣.** បង្គាប់ឲ្យលោក ផែង វណ្ណៈ ចូលខ្លួនទទួលវគ្គបណ្តុះបណ្តាលស្តីពីការរាយការណ៍ព័ត៌មានដែលយល់ដឹងត្រឹមត្រូវអំពីយេនឌ័រក្នុងវិស័យសារព័ត៌មាន ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រុមការងារដើម្បីអនុវត្ត ពិនិត្យ តាមដាន ដោះស្រាយបញ្ហានៃការរំលោភបំពានលើក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពីអំពើហិង្សាលើស្ត្រី។

**សម្រាប់ព័ត៌មានបន្ថែម៖**


| | | |
|---|---|---|
| អេង ចាន់ឌី | នាយិកាអង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា | 095 797 909 |
| បុណ្យ រចនា | នាយិកាប្រតិបត្តិអង្គការក្លាហាន | 089 476 146 |
| ជឹម ចាន់នាង | អគ្គលេខាធិការអង្គការ អិនជីអូ ស៊ី- ដ | 012 668 853 |
| ស្តើង ភារ៉ុង | នាយិកាប្រតិបត្តិអង្គការបន្ទាយស្រី | 081 885 874 |

**លិខិតចំហនេះគាំទ្រដោយ៖**

១. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់លើស្ត្រី(NGO -CEDAW)
២. អង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)
៣. អង្គការ ក្លាហាន (Klahaan)
៤. អង្គការ បន្ទាយស្រី (Banteay Srei)
៥. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍(BCV)
៦. អង្គការនារីដើម្បីសន្តិភាព (WPM)
៧. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)
៨. អង្គការលើកកម្ពស់គុណភាពជីវិត
៩. សមគមគាំពារស្ត្រីងាយរងគ្រោះ (ASVW)
១០. សហភាពការងារកម្ពុជា(CLC)
១១. សមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
១២. គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ (និកហ្វិក)
១៣. សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
១៤. អង្គការ អាក់សិនអេតកម្ពុជា (ActionAid Cambodia)
១៥. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
១៦. បណ្តាញយុវជនកម្ពុជា (CYN)
១៧. មណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC)
១៨. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ (LRSU)
១៩. អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
២០. អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC)
២១. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
២២. បណ្តាញយេនឌ័រ និងអភិវឌ្ឍន៍ (GADNet)
២៣. ក្រុមសន្សំប្រាក់នារី(LSG)
២៤. អង្គការកម្ពុជាដើម្បីសុខភាពនិងការអប់រំសហគមន៍ (CHEC)
២៥. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID)
២៦. អង្គការសម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជា (ANSA Cambodia)
២៧. អង្គការសមាគមន៍ជាងត្នោត (STT)
២៨. អង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (LSCW)
២៩. អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
៣០.សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC Cambodia)
៣១. អង្គការតម្លាភាពកម្ពុជាកម្ពុជា (TIC)
៣២. អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង (UPWD)
៣៣. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (សមាគមអាដហុក)
៣៤. អង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ (SACD)
៣៥. អង្គការគ្រួសត្រាយនៃកម្ពុជា
៣៦. សហគមន៍175គ្រួសារ
៣៧. ស.គ 197គ្រួសារសហគមន៍ភូមិព្រលាន
៣៨. គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)
៣៩.អង្គការមជ្ឈមណ្ឌលសម្ពន្ធ័ភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់)
៤០.អង្គការសីលការ (Silaka)
៤១. អង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍ (PAD)
៤២.បណ្តាញពហុវិស័យ
៤៣.សហគមន៍៨៤៣គ្រួសារខេត្តកោះកុង
៤៤.សហគមន៍១២៩គ្រួសារខេត្តកោះកុង
៤៥. សហគមន៍៨០គ្រួសារ ខេត្តកោះកុង